អេស៊ីលីដា ត្រេននីង សេនធ័រ
ACLEDA Training Center Ltd.

**ការិយាល័យកណ្តាល**

លេខ : អត្រស ១៨៦៦ /១៤

**អគ្គនាយក អេស៊ីលីដា ត្រេននីង សេនធ័រ**

**គោរពជូន**

**តំណាងសមាជិក-សមាជិកាក្រុមគ្រូហ្វឹកហ្វឺននៃ ការិយាល័យរដ្ឋបាល វិស្វកម្ម
ការិយាល័យពិធីការ និងសុខុមាលភាព និងការិយាល័យធនធានមនុស្ស**

**កម្មវត្ថុ :** **វគ្គហ្វឹកហ្វឺនការងារដំបូងសម្រាប់កម្មករនិយោជិតដែលត្រូវបានដំឡើងថ្នាក់នៅជា ប្រធាន-អនុប្រធានជំនួយការបម្រើអតិថិជនសាខា ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខារាជធានី និង សាខាស្រុកកម្រិត " ក "** ( Off-Class Training )

**យោង** :
- សេចក្តីសម្រេចលេខ : អត្រស ០៩៧/១៤ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវគោលការណ៍ប្រតិបត្តិ ហ្វឹកហ្វឺន និងអភិវឌ្ឍន៍ធនធានមនុស្ស ។
- អនុស្សរណៈនៃការយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការ និងគាំទ្រ លើសេវាហ្វឹកហ្វឺនផ្ទៃក្នុងកម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី រវាង ធនាគារ អេស៊ីលីដា ភីអិលស៊ី និង អេស៊ីលីដា ត្រេននីង សេនធ័រ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៣ និងការធ្វើវិសោធនកម្ម ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៣ ។
- សេចក្តីសម្រេចលេខ : អត្រស ០៨៧/១៤ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវកម្មវិធីហ្វឹកហ្វឺនការងារដំបូង សម្រាប់កម្មករនិយោជិត ដែលត្រូវបានដំឡើងថ្នាក់ និង/ឬផ្លាស់ប្តូរមុខតំណែង នៅលំដាប់សាខា ធនាគារ អេស៊ីលីដា ភីអិលស៊ី ។
- លិខិតលេខ : កធម ២១២០/១៤ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីតម្រូវការផ្តល់ការហ្វឹកហ្វឺនការងារដំបូងដល់កម្មករនិយោជិតដែលត្រូវផ្លាស់ប្តូរមុខតំណែង/ ដំឡើងលំដាប់ថ្នាក់ ។
- លិខិតលេខ : កធម ២១៧៥/១៤ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីតម្រូវការផ្តល់ការហ្វឹកហ្វឺនការងារដំបូងដល់កម្មករនិយោជិតដែលត្រូវផ្លាស់ប្តូរមុខតំណែង/ ដំឡើងលំដាប់ថ្នាក់ ។
- លិខិតលេខ : កធម ២២៦០/១៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៤ ស្តីពីតម្រូវការផ្តល់ការហ្វឹកហ្វឺនការងារដំបូងដល់កម្មករនិយោជិតដែលត្រូវផ្លាស់ប្តូរមុខតំណែង/ ដំឡើងលំដាប់ថ្នាក់ ។
- តម្រូវការចាំបាច់ ដើម្បីឲ្យកម្មករនិយោជិតដែលត្រូវបានដំឡើងថ្នាក់ ឬផ្លាស់ប្តូរមុខតំណែងទទួលបាននូវចំណេះដឹង ជំនាញ ស្របតាមមុខតំណែង ។

តបតាមកម្មវត្ថុ និងយោងខាងលើ អេស៊ីលីដា ត្រេននីង សេនធ័រ នឹងមានរៀបចំបើកវគ្គហ្វឹកហ្វឺនការងារដំបូង ( Off-Class Training ) សម្រាប់កម្មករនិយោជិតដែលត្រូវបានដំឡើងថ្នាក់ជា **ប្រធាន-អនុប្រធានជំនួយការបម្រើអតិថិជនសាខា ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខារាជធានី និងសាខាស្រុកកម្រិត " ក "** ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| **១- លោក ឃួន ចំរើន** | ប្រធានជំនួយការបម្រើអតិថិជន | សាខាស្រុកថ្មពួក-ឃុំថ្មពួក |

| | | |
|---|---|---|
| **២- លោក យ៉ាយ រ៉ន** | ប្រធានជំនួយការបម្រើអតិថិជន | សាខាដូនពេញ |
| **៣- លោក អន គង់** | អនុប្រធានជំនួយការបម្រើអតិថិជន | សាខាទី២ឫស្សីកែវ |

នៅ**ការិយាល័យរដ្ឋបាល ការិយាល័យវិស្វកម្ម ការិយាល័យធនធានមនុស្ស និងការិយាល័យពិធីការ និងសុខុមាលភាព** ចាប់ពី**ថ្ងៃទី ១៨ ដល់ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៤** ។

អាស្រ័យហេតុនេះ សូមតំណាងសមាជិក-សមាជិកាក្រុមគ្រូហ្វឹកហ្វឺន មេត្តាចាត់ចែងបណ្តល់ការហ្វឹកហ្វឺនដល់កម្មករ-និយោជិតដែលមានមុខតំណែងដូចបានរៀបរាប់ខាងលើតាមកាលបរិច្ឆេទនិងទីកន្លែងដូចបានជម្រាបជូន ។

សូមតំណាងសមាជិក-សមាជិកាក្រុមគ្រូហ្វឹកហ្វឺន ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ភ្នំពេញ, ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤

**ជ, អគ្គនាយក**

**នាយិកាការិយាល័យសិក្សា និងកិច្ចការនិស្សិត**

This is an electronic letter sent by Sovanne Tourt

**<u>ជូនភ្ជាប់មកជាមួយ</u>**

- កាលវិភាគវគ្គហ្វឹកហ្វឺន

**<u>ចម្លងជូន</u>**

- នាយក ធនាគារ អេស៊ីលីដា សាខាខេត្តបន្ទាយមានជ័យ, សាខាដូនពេញ, និងសាខាទី២ឫស្សីកែវ
  " **ដើម្បីជ្រាបជាព័ត៌មាន និងចាត់បញ្ជូន** "
- ឯកសារ-កាលប្បវត្តិ